ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

# សាលក្រមព្រហ្មទណ្ឌ

សាលក្រមព្រហ្មទណ្ឌ
លេខ: ២៤១ "ជ"
ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ ១០១២
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣
-សំណុំរឿងស៊ើបសួរលេខ ៦៤២
ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ៦២
ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

-កាលបរិច្ឆេទបើកសវនាការ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ វេលារសៀល នាសាលសវនាការ នៃសាលាដំបូងខេត្តកំពត ។

-កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤ វេលារសៀល ។

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពត

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

ដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខ ១០១២ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣ សំណុំរឿងជំនុំជម្រះលេខ ៦២ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពត ដែលមាន៖

**ជនជាប់ចោទ៖**

១. ឈ្មោះ [redacted] ចិត្រា ភេទប្រុស (កើតឆ្នាំ២០០៩) អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពត ទីលំនៅមុនពេលឃាត់ខ្លួនភូមិបើន ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះ [redacted] ស៊ីណា ហៅ ឆ្នុក (ស្លាប់) ម្តាយឈ្មោះ [redacted] សុភឿន (រស់) ស្ថានភាពគ្រួសារ នៅលីវ ជាអនីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

-ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៩៣ (ដ) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣។

២. ឈ្មោះ [redacted] មានស៊ី ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៧ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត ទីលំនៅមុនពេលឃាត់ខ្លួនភូមិបើន ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះ [redacted] ស៊ីណិត (រស់) ម្តាយឈ្មោះ [redacted] ចន្ទូ (រស់) ស្ថានភាពគ្រួសារ នៅលីវ ជាអនីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

-ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៨៩ (ដ) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣។

៣. ឈ្មោះ [redacted] វឌ្ឍនា ហៅ ធី ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងអគ្គិសនី ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត ទីលំនៅមុនពេលឃាត់ខ្លួនភូមិចង្អៀងខាងកើត ឃុំទទុង ស្រុកដងទង់ ខេត្តកំពត ឪពុកឈ្មោះ [redacted] ថុ (រស់) ម្តាយឈ្មោះ [redacted] គោក (រស់) ស្ថានភាពគ្រួសារ នៅលីវ ជាអនីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

-ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៩១ (ដ) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣។



Scanned with CamScanner

ត្រូវជាប់ចោទពីបទ កាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិបក្កុង ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

**មេធាវី**

លោក [redacted] ជាសមាជិកគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា ការិយាល័យមេធាវី ចាន់ វិចិត្រ ផ្ទះលេខអគារលេខ ១១A ជាន់ទី២ ផ្លូវលេខ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ចិត្រា និងឈ្មោះ [redacted] មានស៊ី។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពត។

-បានឃើញ ដីកាដំណោះស្រាយ លេខ ៦០ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត។

-បានឃើញ ការចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៤៣ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពត។

## អង្គហេតុដែលប្តឹងមកតុលាការ

កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅភូមិបក្កុង ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត មានករណី កាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ដែលបង្កឡើងដោយជនត្រូវចោទឈ្មោះ [redacted] ចិត្រា ភេទប្រុស អាយុ ១៩ឆ្នាំ, ជនត្រូវចោទឈ្មោះ [redacted] មានស៊ី ភេទប្រុស អាយុ ១៧ឆ្នាំ និងជនត្រូវចោទឈ្មោះ [redacted] វឌ្ឍនា ហៅ ជី ភេទប្រុស អាយុ ១៩ឆ្នាំ ដោយឈ្មោះ [redacted] ចិត្រា បានដាក់កាំបិតប៉ុងតោ ចំនួន ០១ ក្នុងកាតាបរបស់ខ្លួន ហើយនាំគ្នាជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ស៊េរីឆ្នាំ២០២០ ពណ៌ខ្មៅ ពាក់ផ្លាកលេខ កំពត 1Q-៦២៩៦ មានគ្នា ០៣នាក់ ចេញពីផ្ទះសំដៅទៅមើលបុណ្យនៅវត្តក្រាំងលាវ ស្ថិតនៅភូមិឃុំខាងលើ។ ពេលជិះទៅដល់ក្នុងបរិវេណវត្តត្រង់ចំណុចក្បែរព្រះវិហារ ដែលគេហាមមិនឲ្យចូល សមត្ថកិច្ចមានការសង្ស័យបានឃាត់ខ្លួន និងឆែកឆេរក្នុងកាតាបរបស់ឈ្មោះ រស់ ចិត្រា ឃើញមានកាំបិតប៉ុងតោ ហើយសមត្ថកិច្ចបានដកហូតកាំបិតប៉ុងតោខាងលើ រួចបញ្ជូនជនត្រូវចោទមកអយ្យការអមសាលាដំបូងខេត្តកំពត តែម្តង។

## នាពេលសវនាការ

- ខ្លឹមសារសង្ខេបនៃចម្លើយជនជាប់ចោទឈ្មោះ [redacted] ចិត្រា បានឆ្លើយថា ខ្លួនទទួលស្គាល់ចំពោះអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់មកលើខ្លួន។ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ខ្លួនបានចេញដំណើរពីផ្ទះទៅវត្តក្រាំងលាវ ដើម្បីទៅលេងបុណ្យកឋិន ហើយពេលនោះខ្លួនក៏បានដាក់កាំបិតប៉ុងតោនៅក្នុងកាតាប ដើម្បីការពារខ្លួន ដោយមូលហេតុខ្លួនខ្លាចមានគេរករឿងខ្លួន ព្រោះខ្លួនធ្លាប់មានបញ្ហាជាមួយមនុស្សរស់នៅជិតវត្តក្រាំងលាវនោះ។ កាំបិតនោះ គឺខ្លួនដាក់នៅក្នុងកាតាបរបស់ខ្លួន។ ខ្លួនក៏បានប្រាប់ឈ្មោះ [redacted] មានស៊ី និងឈ្មោះ [redacted] វឌ្ឍនា ថាខ្លួនបានដាក់កាំបិតនៅក្នុងកាតាបដែរ ហើយខ្លួនក៏បានប្រាប់ថាខ្លួនយកកាំបិតទៅដើម្បីការពារខ្លួន។ ពួកខ្លួន មិនបានណាត់គ្នាដើម្បីកាប់គ្នានោះទេ តែដោយសារតែក្រុមម្ខាងទៀត បានគម្រាមខ្លួន ទើបខ្លួនបានដាក់កាំបិតទុកការពារ។ ខ្លួនសូមបញ្ជាក់ផងដែរថា ខ្លួនមិនទាន់បង្កហេតុទៅលើបុគ្គលណានោះទេ។ បន្ទាប់ពីឃាត់ខ្លួន មកសមត្ថកិច្ចបានតេស្តទឹកនោមខ្លួន គឺមិនមានសារធាតុញៀននោះទេ។

- ខ្លឹមសារសង្ខេបនៃចម្លើយជនជាប់ចោទឈ្មោះ [redacted] មានស៊ី បានឆ្លើយថា ខ្លួនទទួលស្គាល់ចំពោះអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់មកលើខ្លួន។ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] ចិត្រា និងឈ្មោះ [redacted] វឌ្ឍនា ដោយឈ្មោះ [redacted] វឌ្ឍនា ជាអ្នកបើកម៉ូតូ។ ពីដំបូងខ្លួនមិនបានដឹងថាឈ្មោះ រស់ ចិត្រា ដាក់កាំបិតទៅតាមខ្លួនក្នុងកាតាបនោះទេ តែក្រោយជិះម៉ូតូចេញទៅ ទើបដឹងថាឈ្មោះ [redacted] ចិត្រា បានដាក់កាំបិតនៅក្នុងកាតាប ដើម្បីការពារខ្លួន។ តែពេលទៅដល់វត្តក៏បានជួបសមត្ថកិច្ច ហើយសមត្ថកិច្ចក៏បានឆែកឆេរ ព្រមទាំងបានឃាត់ខ្លួនតែម្តង។ បន្ទាប់ពីឃាត់ខ្លួនមក សមត្ថកិច្ចបានតេស្តទឹកនោមខ្លួន គឺមិនមានសារធាតុញៀននោះទេ។



Scanned with CamScanner

-ខ្លឹមសារសង្ខេបនៃចម្លើយជនជាប់ចោទឈ្មោះ [redacted] វណ្ណនា ហៅ ធី បានឆ្លើយថា ខ្លួនទទួលស្គាល់ចំពោះអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់មកលើខ្លួន។ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ គឺខ្លួនជាអ្នកបើកម៉ូតូទៅជាមួយឈ្មោះ [redacted] ចិត្រា និងឈ្មោះ ណុន មានស៊ុំ ហើយខ្លួនក៏បានដឹងថាឈ្មោះ រស់ ចិត្រា ដាក់កាំបិតទៅដែរ តែពេលសួរទៅឈ្មោះ [redacted] ចិត្រា គាត់ក៏បានឆ្លើយថាទុកការពារខ្លួន។ ខ្លួនមិនធ្លាប់មានបញ្ហាជាមួយអ្នកណានោះទេ តែឈ្មោះ រស់ ចិត្រា ថាគាត់ធ្លាប់មានបញ្ហាជាមួយមនុស្សរស់នៅជិតវត្តនោះ ទើបគាត់ដាក់កាំបិតទៅតាមខ្លួន។ បន្ទាប់ពីឃាត់ខ្លួនមកសមត្ថកិច្ចបានតេស្តទឹកនោមខ្លួន គឺមិនមានសារធាតុញៀននោះទេ។

-ខ្លឹមសារសង្ខេបនៃសេចក្តីសន្និដ្ឋានការពាររបស់លោក [redacted] សាម៉ីឌី មេធាវីការសិទ្ធិឲ្យជនជាប់ចោទ ឈ្មោះ [redacted] ចិត្រា និងឈ្មោះ [redacted] មានស៊ុំ ថាកូនក្តីខ្លួនបានឆ្លើយសារភាពទទួលស្គាល់កំហុសរបស់ខ្លួន ម្យ៉ាងវិញទៀតកូនក្តីខ្លួនជាអនីតិជន និងសូមស្នើសុំតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន។

-ខ្លឹមសារសង្ខេបនៃសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការៈ ក្រោយពីបានស្តាប់ចម្លើយសារភាពជនជាប់ចោទនាពេលសវនាការឃើញថា ជនជាប់ចោទបានសារភាពនូវកំហុសរបស់ខ្លួន ហេតុនេះតំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់ ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ២២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ទុកជាបានការដដែល និងសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-សំដីសំណូមពរចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្រា ថា ស្នើសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោស ខ្លួននឹងកែប្រែខ្លួនឡើងវិញ។

-សំដីសំណូមពរចុងក្រោយរបស់ជនជាប់ចោទឈ្មោះ ណុន មានស៊ុំ ថា ស្នើសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោស ខ្លួននឹងកែប្រែខ្លួនឡើងវិញ។

-សំដីសំណូមពរចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណនា ហៅ ធី ថា ស្នើសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោស ខ្លួននឹងកែប្រែខ្លួនឡើងវិញ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំណូមពរសម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានធ្វើមូលវិចារណ៍ ពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-ផ្អែកតាមដីកាដំណោះស្រាយលេខ ៦០ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពត បានសម្រេចបញ្ជូន បុគ្គល និងអង្គហេតុ មកសាលាដំបូងខេត្តកំពត ដើម្បីជំនុំជម្រះ ពីបទ កាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិបក្អុង ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចិត្រា, ជនជាប់ចោទឈ្មោះ [redacted] មានស៊ុំ និងជនជាប់ចោទឈ្មោះ [redacted] វណ្ណនា ហៅ ធី ដែលតុលាការព្រហ្មទណ្ឌ នៃសាលាដំបូងខេត្តកំពត អាចលើកយកមកបើកសវនាការជំនុំជម្រះបានតាមបញ្ញត្តិមាត្រា ២៩១ មាត្រា ៣៤៨ និងមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្រា នាពេលសវនាការឆ្លើយថា ខ្លួនទទួលស្គាល់ចំពោះអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់មកលើខ្លួន ដោយកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ខ្លួនបានធ្វើដំណើរពីផ្ទះទៅវត្តក្រាំងលាវ ដើម្បីទៅលេងបុណ្យកឋិន ហើយពេលនោះខ្លួនក៏បានដាក់កាំបិតប៉ុងតោនៅក្នុងកាតាប ដើម្បីការពារខ្លួន ដោយមូលហេតុខ្លួនខ្លាចមានគេរករឿងខ្លួន ព្រោះខ្លួនធ្លាប់មានបញ្ហាជាមួយមនុស្សរស់នៅជិតវត្តក្រាំងលាវនោះ។ កាំបិតនោះ គឺខ្លួនដាក់នៅក្នុងកាតាបរបស់ខ្លួន។ ខ្លួនក៏បានប្រាប់ឈ្មោះ [redacted] មានស៊ុំ និងឈ្មោះ [redacted] វណ្ណនា



Scanned with CamScanner

ថាខ្លួនបានដាក់កាំបិតនៅក្នុងកាតាបដែរ ហើយខ្លួនក៏បានប្រាប់ថាខ្លួនយកកាំបិតទៅដើម្បីការពារខ្លួន។ ម្យ៉ាងវិញទៀត តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មានស៊ុំ នាពេលសវនាការបានឆ្លើយសារភាពថា ខ្លួនទទួលស្គាល់ចំពោះអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់មកលើខ្លួន។ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] ចិត្រា និងឈ្មោះ [redacted] វឌ្ឍនា ដោយឈ្មោះ [redacted] វឌ្ឍនា ជាអ្នកបើកម៉ូតូ។ ពីដំបូងខ្លួនមិនបានដឹងថាឈ្មោះ [redacted] ចិត្រា ដាក់កាំបិតទៅតាមខ្លួនក្នុងកាតាបនោះទេ តែក្រោយជិះម៉ូតូចេញទៅ ទើបដឹងថាឈ្មោះ [redacted] ចិត្រា បានដាក់កាំបិតនៅក្នុងកាតាប ដើម្បីការពារខ្លួន។ តែពេលទៅដល់វត្តក៏បានជួបសមត្ថកិច្ច ហើយសមត្ថកិច្ចក៏បានឆែកឆេរ ព្រមទាំងបានឃាត់ខ្លួនតែម្តង។ គាន់តែមានភាពស៊ីសង្វាក់គ្នា ជាមួយចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនា ហៅ វី ថា ខ្លួនទទួលស្គាល់ចំពោះអង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់មកលើខ្លួន។ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ គឺខ្លួនជាអ្នកបើកម៉ូតូទៅជាមួយឈ្មោះ [redacted] ចិត្រា និងឈ្មោះ [redacted] មានស៊ុំ ហើយខ្លួនក៏បានដឹងថាឈ្មោះ [redacted] ចិត្រា ដាក់កាំបិតទៅដែរ តែពេលសួរទៅឈ្មោះ [redacted] ចិត្រា គាត់ក៏បានឆ្លើយថាទុកការពារខ្លួន។ ខ្លួនមិនធ្លាប់មានបញ្ហាជាមួយអ្នកណានោះទេ តែឈ្មោះ [redacted] ចិត្រា ថាគាត់ធ្លាប់មានបញ្ហាជាមួយមនុស្សរស់នៅជិតវត្តនោះ ទើបគាត់ដាក់កាំបិតទៅតាមខ្លួន។

៣-យល់ឃើញថា អំពើរបស់ជនជាប់ចោទ បង្ហាញឱ្យឃើញពីចេតនាទុច្ចរិតក្នុងការយកតាមខ្លួន ឬដឹកជញ្ជូនអាវុធ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ដែលធ្វើឲ្យប៉ះពាល់ ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គមផងដែរ។

៤-យល់ឃើញថា ជនជាប់ចោទមាននីតិសម្បទាគ្រប់គ្រាន់ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជនជាប់ចោទមានបញ្ហាវិបល្លាស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ចិត្រា និងឈ្មោះ [redacted] មានស៊ុំ ជាអនីតិជន ការសម្រេចផ្តន្ទាទោសលើបទល្មើស មូលទោសត្រូវបានកាត់បន្ថយពាក់កណ្តាល។ តុលាការ គប្បីពិចារណាដោយផ្អែកតាម មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

៥-យល់ឃើញថា មានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដើម្បីប្រកាសពីពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] ចិត្រា, ឈ្មោះ [redacted] មានស៊ុំ និងឈ្មោះ [redacted] វឌ្ឍនា ហៅ វី ពីបទ កាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិបរក្សុង ឃុំអង្គមាស ស្រុកជងទង់ ខេត្តកំពត កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

៦-យល់ឃើញថា តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការនាពេលសវនាការ ដែលបានលើកឡើងអំពីអង្គហេតុ និងអង្គច្បាប់ ព្រមទាំងភស្តុតាងដាក់បន្ទុកមួយចំនួនលើជនជាប់ចោទខាងលើ ស្នើសុំតម្កល់បទចោទដូចក្នុងដីកាសន្និដ្ឋានស្ថាពរ ទុកជាបានការដដែល និងសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ គប្បីតុលាការពិចារណា និងសម្រេចដោយផ្អែកតាមអង្គហេតុ និងអង្គច្បាប់។

៧-តាមសេចក្តីសន្និដ្ឋានការពាររបស់លោក [redacted] សាម៉ឺឌី បានស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួនផង។ គប្បីតុលាការពិចារណា និងសម្រេចដោយផ្អែកតាមអង្គហេតុ និងអង្គច្បាប់។

៨-តាមសម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្រា, ឈ្មោះ [redacted] មានស៊ុំ និងឈ្មោះ [redacted] វឌ្ឍនា ហៅ វី បាននិយាយសំដីប្រហាក់ប្រហែលគ្នា ស្នើសុំឲ្យតុលាការបន្ធូរបន្ថយទោស។ គប្បីតុលាការ លើកយកការស្នើសុំនេះ មកពិចារណា ដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់។

៩-យល់ឃើញថា បទល្មើសដែលជនជាប់ចោទខាងលើ គឺជាអំពើ កាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ហើយគប្បីតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ដោយឈរលើគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍ឯកត្តកម្មនៃទោស តាមបញ្ញត្តិមាត្រា២៤ មាត្រា៩៦ និង មាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ដើម្បីជាការព្រមាន អប់រំ និងកែប្រែជនជាប់ចោទកុំឱ្យប្រព្រឹត្តអំពើខាងលើសារជាថ្មី។



Scanned with CamScanner

១០.បរល់ឃើញថា តាមដីកាបង្គាប់ឱ្យរក្សាទុកវត្ថុតាងលេខ ៣៩៨៤ ព្រ.ទ/២៣ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពត បានបង្គាប់ឱ្យប្រធានលេខាធិការដ្ឋានសាលាដំបូងខេត្តកំពត ទទួលថែរក្សាវត្ថុចាប់យកមាន៖ កាតាបស្ពាយខាងក្រោយពណ៌ខ្មៅ ចំនួន ០១ (មួយ) ជារបស់ឈ្មោះ [redacted] ចិត្រា, ខោកាបិយ ចំនួន ០១ (មួយ) ជារបស់ឈ្មោះ [redacted] ចិត្រា, ទូរស័ព្ទម៉ាក VIVO ពណ៌ខ្មៅ ចំនួន ០១ (មួយ) គ្រឿង ជារបស់ឈ្មោះ [redacted] ចិត្រា, ម៉ូតូម៉ាកហុងដា សេ ១២៥ ស៊េរីឆ្នាំ២០២០ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ១Q-៦២៩៦ ចំនួន ០១ (មួយ) គ្រឿង ជារបស់ឈ្មោះ [redacted] វឌ្ឍនា និងទូរស័ព្ទម៉ាក Iphone 8+ ពណ៌ស ចំនួន ០១ (មួយ) គ្រឿង ជារបស់ឈ្មោះ [redacted] វឌ្ឍនា។ តុលាការសម្រេចប្រគល់ឱ្យទៅម្ចាស់ដើមវិញ។

ដោយឡែក កាំបិតប៉ុងតោ ចំនួន ០១ (មួយ) ជារបស់ឈ្មោះ [redacted] ចិត្រា ដែលជនជាប់ចោទបានប្រើប្រាស់ជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស តុលាការ សម្រេចរឹបអូស។

*(ផ្នែកខាងក្រោមនេះត្រូវបានទុកនៅទំនេរដោយចេតនា)*



Scanned with CamScanner

**សេចក្តីសម្រេច**

**ហេតុដូច្នេះ សាលាដំបូងខេត្តកំពត សម្រេច**

**១-ប្រកាសថាមានពិរុទ្ធភាពលើជនជាប់ចោទ និងផ្តន្ទាទោសលើជនជាប់ចោទ៖**

១.១. ឈ្មោះ [redacted] ចិត្រា ភេទប្រុស (កើតឆ្នាំ២០០៩) អាយុ ១៥ឆ្នាំ *(មានអត្តសញ្ញាណដូចខាងលើ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៩៣ (ដ) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣)* ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ខែ និងពិន័យជាប្រាក់ចំនួន ៥០០.០០០ (ប្រាំសែន) រៀល ។

១.២. ឈ្មោះ [redacted] មានស៊ី ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៧ឆ្នាំ) *(មានអត្តសញ្ញាណដូចខាងលើ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៨៩ (ដ) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣)* ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ខែ និងពិន័យជាប្រាក់ចំនួន ៥០០.០០០ (ប្រាំសែន) រៀល ។

១.៣. ឈ្មោះ [redacted] វឌ្ឍនា ហៅ ជី ភេទប្រុស អាយុ ១៩ឆ្នាំ *(មានអត្តសញ្ញាណដូចខាងលើ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៩១ (ដ) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣)* ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ។

ពីបទ កាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិបរក្នុង ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

**២-រឹបអូសវត្ថុចាប់យក៖**

- កាំបិតប៉ុងតោ ចំនួន ០១ (មួយ) ជារបស់ឈ្មោះ [redacted] ចិត្រា។

**៣-សម្រេចប្រគល់វត្ថុចាប់យកឲ្យម្ចាស់ដើមវិញ៖**

- កាតាបស្ពាយខាងក្រោយពណ៌ខ្មៅ ចំនួន ០១ (មួយ) ជារបស់ឈ្មោះ [redacted] ចិត្រា ។
- ខោកាប៊ូយ ចំនួន ០១ (មួយ) ជារបស់ឈ្មោះ [redacted] ចិត្រា។
- ទូរស័ព្ទម៉ាក VIVO ពណ៌ខ្មៅ ចំនួន ០១ (មួយ) គ្រឿង ជារបស់ឈ្មោះ [redacted] ចិត្រា។
- ម៉ូតូម៉ាកហុងដា សេ ១២៥ ស៊េរីឆ្នាំ២០២០ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ១Q-៦២៩៦ ចំនួន ០១ (មួយ) គ្រឿង ជារបស់ឈ្មោះ [redacted] វឌ្ឍនា។
- ទូរស័ព្ទម៉ាក Iphone 8+ ពណ៌ស ចំនួន ០១ (មួយ) គ្រឿង ជារបស់ឈ្មោះ [redacted] វឌ្ឍនា។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចិត្រា, ឈ្មោះ [redacted] មានស៊ី និងឈ្មោះ [redacted] វឌ្ឍនា ហៅ ជី។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅកំពត,ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner